**BMI0056**

# សម្ភាសន៍ជាមួយឈ្មោះ ប្រាក់ ឈាន ភេទប្រុស អាយុ៥៣ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ ធ្វើស្រែនៅភ្នំបាសិត

មុខងារបច្ចុប្បន្នៈ កសិករ

ស្រុកកំណើតនៅភូមិក្បាលកោះ ឃុំកោះជ្រែង ស្រុកក្រចេះ ខេត្តក្រចេះ

សព្វថ្ងៃរស់នៅភូមិវាលហាត់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ហ៊ិន សុធានី

០០:៥៣:៣៣

២៨ទំព័រ

ធានី ៖ ថ្ងៃហ្នឹងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០។ ពួកខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយពួកខ្ញុំចុះមកនេះ ពួកខ្ញុំចង់សាកសួរពូពីប្រវត្តិលោកពូកាលលោលកពូឆ្លងកាត់រហូតមកដល់ស្រុកម៉ាឡៃនេះ តើមានរឿងអីកើតឡើង តើពូជួបការលំបាកអីខ្លះ ហើយពូឃើញទិដ្ឋភាពយ៉ាងម៉េចនៅស្រុកម៉ាឡៃនឹង។ ហើយរឿងរ៉ាវដែលពូបានប្រាប់ពួកខ្ញុំ ពួកខ្ញុំយកទៅសរសេរជាសៀវភៅ ក៏ដូចជាសិក្សាប្អូសម្រាប់ក្មេងៗ អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយបានអានបានដឹង។ តើពូអនុញ្ញាតិឲ្យពួកខ្ញុំយកទៅប្រើប្រាស់ធ្វើជាសៀវភៅអីបានទេ?

ឈាន ៖ បាន អត់អីទេ។

ធានី ៖ ហើយពួកខ្ញុំសុំថតជាសម្លេង ថតជាវីដេអូ ក៏ដូចជាថតជាសម្លេង ថតជារូបថតបានទេ?

ឈាន ៖ បាន។

ធានី ៖ ពូមានឈ្មោះអី?

ឈាន ៖ ខ្ញុំឈ្មោះ ប្រាក់ ឈាន។

ធានី ៖ ពូអាយុប៉ុន្មានហើយ?

ឈាន ៖ ៥៣។

ធានី ៖ ពូមានស្រុកកំណើតនៅណា?

ឈាន ៖ ខ្ញុំនៅក្រចេះ ភូមិក្បាលកោះ ឃុំកោះជ្រែង ស្រុកក្រចេះ ខេត្តក្រចេះ។

ធានី ៖ សព្វថ្ងៃពូនៅណាដែរ?

ឈាន ៖ សព្វថ្ងៃខ្ញុំនៅម៉ាឡៃ។

ធានី ៖ នៅភូមិឃុំអីដែរ?

ឈាន ៖ ភូមិវាលហាត់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ធានី ៖ ឪពុកពូឈ្មោះអី?

ឈាន ៖ ឪពុកខ្ញុំឈ្មោះ ប្រាក់ ឈាក ។ ម្ដាយឈ្មោះ សា ស្ដៅ ។

ធានី ៖ ឪពុកពូស្លាប់ពេលណា?

ឈាន ៖ ស្លាប់យូរដែរហើយ ស្លាប់តាំងពី៧៤ ៧៥ ។

ធានី ៖ ចុះម្ដាយពូ?

ឈាន ៖ ម្ដាយក៏ស្លាប់ ។

ធានី ៖ ពេលណា?

ឈាន ៖ អាចរ៨៣ ៨៤ ។

ធានី ៖ មិនមែន៨៥ ៨៦?

ឈាន ៖ អឺ! ៨៥ ៨៦នេះឯង ។

ធានី ៖ គាត់ស្លាប់ដោយសារអី?

ឈាន ៖ គាត់ចាស់ ។

ធានី ៖ ពូមានបងប្អូនប៉ុន្មាននាក់?

ឈាន ៖ មាន៦ ប្រុស៣ ស្រី៣ ។

ធានី ៖ គាត់នៅរស់ទាំងអស់?

ឈាន ៖ ប៉ុនស្លាប់មួយហើយ ។

ធានី ៖ ស្លាប់ស្រីមួយ?

ឈាន ៖ បាទ!

ធានី ៖ ដោយសារអីដែរ?

ឈាន ៖ អត់ដឹងដែរ ព្រោះនៅបែកគ្នាពីគាត់ ។

ធានី ៖ ពូបានរៀនចេះអានចេះអីទេ?

ឈាន ៖ ចេះសរសេរអក្សរបានខ្លះ រៀនថ្នាក់ទី១០ ។

ធានី ៖ នៅណាវិញ រៀន?

ឈាន ៖ រៀននៅស្រុកកំណើត ។

ធានី ៖ នៅសាលាអីដែរ?

ឈាន ៖ នៅសាលាបឋមសិក្សាគាមភូមិ ។

ធានី ៖ ចាំឈ្មោះសាលារៀននឹងទេ?

ឈាន ៖ បឋមសិក្សាឃុំកោះជ្រែង ។

ធានី ៖ ម៉េចបានពូមកដល់នៅម៉ាឡៃ?

ឈាន ៖ នេះនិយាយពីប្រវត្តិព្រោះថាកាលនោះជំនាន់សង្គ្រាម ម្តាយនៅដោយម្តាយ ហើយកូនចៅក៏បែកបាក់គ្នា ហើយខ្ញុំចេះបែកចេញមករហូត រសាត់រហូតមកទល់សម័យសព្វថ្ងៃនេះ ។ ដែលខ្ញុំមកឈរជើងនៅជាប់នឹងទឹកដីម៉ាឡៃនេះគឺឆ្នាំ៧៩-៩០ អឺ!៨៩-៩០រហូតដល់សមាហរណកម្ម ។ ហើយទិដ្ឋភាពដើមនៅស្រុកម៉ាឡៃនេះ ខ្ញុំជម្រាបថាពីដើមវាព្រៃមែន ព្រៃខ្លាំង ហើយសូម្បីតែមនុស្សក៏មិនសូវមានដែរ ហើយកាលនោះវាមានជម្ងឺច្រើនណាស់ ហើយមនុស្សក៏ស្លាប់ច្រើន ហើយតាមស្រុក តាមភូមិនេះ ក៏សុទ្ធតែព្រៃទាំងអស់ អត់មានផ្លូវដើរ អត់មានការចិញ្ចឹមសត្វ ចិញ្ចឹមស្អីៗក៏អត់មានទេ ។ សូម្បីតែសាលារៀនក៏គ្មានផង ជាក់ស្តែងកូនខ្ញុំតូចកាលនៅតូចៗអត់មានសាលារៀនទេ ។ ទើបនៅក្រោយសមាហរណកម្ម ដែលរាជរដ្ឋាភិបាលគាត់រៀបចំស្រួលបួលត្រឹមត្រូវបានកូនចេះរៀនសូត្រ ចេះអក្សរចេះអាន ។ តែឥឡូវវាធំៗអស់ហើយ គ្មានធ្វើការងារទេ មានតែធ្វើចំការស្រែធម្មតា ។

ធានី ៖ ដំបូងបំផុតមកស្រុកម៉ាឡៃនេះ មកឆ្នាំប៉ុន្មាន?

ឈាន ៖ ដំបូងបំផុតខ្ញុំមកពីឆ្នាំ៧៩ តែខ្ញុំមកនៅបានប្រហែលជាកន្លះខែទេ នៅព្រំដែនម៉ាឡៃថៃ ក្រោយមកខ្ញុំទៅនៅដងរែក ។

ធានី ៖ ឆ្នាំប៉ុន្មានដងរែក?

ឈាន ៖ ឆ្នាំ៧៩ដែរ ប៉ុនកាលនោះខែ១១ ឆ្នាំ៧៩ ។ ដល់ខែ១២ខ្ញុំទៅនៅដងរែក ។

ធានី ៖ ខែ១២មកនៅដងរែក អីចឹងមកម៉ាឡៃនៅខែ១១?

ឈាន ៖ បាទ! ទៅនៅដងរែករហូតដល់ឆ្នាំ៨២បានខ្ញុំវិលត្រឡប់មកវិញ ។

ធានី ៖ វិលទៅណា?

ឈាន ៖ វិលមកនៅម៉ាឡៃវិញ ។ ខ្ញុំមកនៅម៉ាឡៃហើយបានមកនៅនឹងរហូតទល់ឆ្នាំ៨៥ ដែលមានសង្គ្រាមបែកបាក់កម្ពុជាជាមួយវៀតណាមនឹងក៏ខ្ញុំទៅថៃទៅ មានប្រជាជនច្រើនទៅរស់នៅ ។ ក្រោយមកដល់៧៩បានខ្ញុំចូលមកវិញ ។

ធានី ៖ ដល់ប៉ុន្មាន?

ឈាន ៖ អឺ! ៨៥ ៨៦ ៨៧ ៨៩ខ្ញុំចូល ។

ធានី ៖ ៨៩ទៅណាវិញ?

ឈាន ៖ ចូលមកនៅម៉ាឡៃ រហូតទល់សព្វថ្ងៃ ។

ធានី ៖ កាលដំបូងពូថា ៧៩ពូមកដល់នេះ?

ឈាន ៖ បាទ!

ធានី ៖ ចុះម៉េចបានពូមកហ្នឹង?

ឈាន ៖ ចុះកាលនឹងសង្គ្រាមដែរ ។

ធានី ៖ សង្គ្រាមយ៉ាងម៉េច?

ឈាន ៖ សង្គ្រាមវៃគ្នារវាងកម្ពុជានិងវៀតណាម ដល់ធ្វើទៅខ្ញុំរស់នៅវាបែកបាក់គ្នារត់រគាយមក ។

ធានី ៖ ដំបូងស្រុកកំណើតពូនៅក្រចេះ?

ឈាន ៖ ហ្នឹងហើយ ភាគច្រើនគេរត់មកច្រើនដែរ ហើយខ្ញុំនៅតូចដែរចេះតាមគេតាមឯង មិនទាន់មានគ្រួសារណា ។

ធានី ៖ មកតាមគេ?

ឈាន ៖ បាទ! ចេះមកៗសោត់នឹងគេមក បងប្អូនបែកបាក់គ្នាទៅរហូតទៅ ។

ធានី ៖ អីចឹងមុន៧៩ ពូនៅក្រចេះ?

ឈាន ៖ មុនឆ្នាំ៧០ ខ្ញុំនៅក្រចេះ ។

ធានី ៖ ពូនៅធ្វើអីគេ?

ឈាន ៖ ខ្ញុំនៅផ្ទះរៀនសូត្រធម្មតា ។

ធានី ៖ កាលនឹងពូអាយុប៉ុន្មាន?

ឈាន ៖ កាលនឹងអាយុ១៧ ១៨ឆ្នាំ ។

ធានី ៖ នៅឆ្នាំ៧០ហ្នឹង?

ឈាន ៖ បាទ! នៅឆ្នាំ៧០យើងមិនសង្គ្រាមរវាងអាមេរិច ដែលលោកលន់ នល់គាត់ ។ ខ្ញុំពូៗតាមនេះទេ សង្គ្រាមនៅខ្មែរនឹងក៏មានទម្លាក់កាប៉ាល់ហោះអីចុះឡើងទៅបែកបាក់គ្នា ខ្ញុំរត់ចេញរហូតមក ហើយចេះតៗមកខ្ញុំអត់មានបាននៅស្រុកណា ។

ធានី ៖ ពូរត់ចេញទៅណា?

ឈាន ៖ ខ្ញុំចុះមកភ្នំពេញ ។

ធានី ៖ មកធ្វើអីគេនៅភ្នំពេញ?

ឈាន ៖ ចុះគេយកមក ។

ធានី ៖ ឆ្នាំប៉ុន្មានគេយកមក?

ឈាន ៖ ឆ្នាំ៧៣ ។

ធានី ៖ ៧៣ មកភ្នំពេញធ្វើអី?

ឈាន ៖ មកនៅធ្វើទាហាន ។

ធានី ៖ ទាហានអីគេ?

ឈាន ៖ ដឹងទាហានអីគេ គេហៅទាហានចេះហៅនឹងគេទៅ ។

ធានី ៖ ទាហានខាងណា ព្រោះពូថាមានវៃជាមួយអាមេរិច?

ឈាន ៖ ជាមួយខ្មែរក្រហម ។

ធានី ៖ ពូជាទាហានខ្មែរក្រហម ឬទាហានណា?

ឈាន ៖ ទាហានខ្មែរក្រហម ។

ធានី ៖ មកភ្នំពេញឆ្នាំ៧៣ហ្នឹង?

ឈាន ៖ បាទ! ប៉ុនខ្ញុំមិនមកដល់ភ្នំពេញទេ ខ្ញុំមកនៅម៉ាជួរភ្នំបាសិត ។

ធានី ៖ ពូនៅកន្លែងនឹងធ្វើអីគេ?

ឈាន ៖ នៅជាទាហាន ។

ធានី ៖ ពេលនឹងពូចូលទាហានមុននឹង ឬចូលពេលមកភ្នំពេញ?

ឈាន ៖ ចូលពេលនឹង ។

ធានី ៖ ពេលមកភ្នំពេញនឹង គឺពូចូលទាហាន?

ឈាន ៖ បាទ!

ធានី ៖ ពូចូកតាមរយៈអ្នកណាគេ?

ឈាន ៖ មិនដឹងរយៈអ្នកណា គេមេៗខ្មែរក្រហមនឹង ។

ធានី ៖ ឈ្មោះអីគេ?

ឈាន ៖ អត់ស្គាល់គេទេ ព្រោះវាយូរហើយ ភ្លេចអស់ហើយ ព្រោះតាមថ្នាក់ៗ ។

ធានី ៖ ម៉ាថ្នាក់ដែលពូស្គាល់ ចាំឈ្មោះគាត់ទេ?

ឈាន ៖ ឈ្មោះ ផល ។

ធានី ៖ ផលជាអ្នកណាគេ?

ឈាន ៖ ជាមេកង ។

ធានី ៖ កងរបស់ពូ?

ឈាន ៖ ហ្នឹងហើយ ។

ធានី ៖ មេកងអីគេ?

ឈាន ៖ កងអនុសេនាតូច ។

ធានី ៖ នៅណាវិញ?

ឈាន ៖ នៅក្រចេះដូចគ្នា ។

ធានី ៖ តែគាត់មកដែរ?

ឈាន ៖ មកដែរ មកជាមួយគ្នា ។

ធានី ៖ អនុសេនាតូចលេខប៉ុន្មាន?

ឈាន ៖ គេហៅ១២០ ។

ធានី ៖ អនុសេនាតូច១២០ ឬកង១២០?

ឈាន ៖ កងអនុសេនាធំ១២០ ។

ធានី ៖ អនុសេនាតូចលេខប៉ុន្មាន?

ឈាន ៖ អនុសេនាតូចទី៣ ។

ធានី ៖ អនុសេនាធំ១២០?

ឈាន ៖ ១២០ ។

ធានី ៖ ចុះវរៈៗ?

ឈាន ៖ អានឹងជាលេខតំបន់ ។

ធានី ៖ តំបន់អីគេ?

ឈាន ៖ តំបន់៥០៥ ។

ធានី ៖ កាលនឹងពូមកភ្នំពេញមកធ្វើអីគេ?

ឈាន ៖ មកជាទាហាន ។

ធានី ៖ មកប៉ុន្មាននាក់?

ឈាន ៖ មកគ្នាច្រើនណាស់ ខ្ញុំស្គាល់រៀបរាប់មិនអស់ ។

ធានី ៖ ប៉ុន្មានកងវរៈ?

ឈាន ៖ វាចំនួន៣កងអនុសេនាតូច ។

ធានី ៖ មានប៉ុន្មាននាក់អនុសេនាតូច?

ឈាន ៖ ម៉ាអនុសេនាតូចមាន៣៦ ។

ធានី ៖ អីចឹង៣កងអនុសេនាតូច?

ឈាន ៖ បាទ! ៣កងអនុសេនាតូច ។

ធានី ៖ ពេលពូមកនឹង បងផលនឹងជាមេដឹកនាំធំ?

ឈាន ៖ អត់ទេ មានទៀត ។

ធានី ៖ តែផលនឹងជាមេកងរបស់ពូ?

ឈាន ៖ ជាមេកងរបស់ខ្ញុំ ។

ធានី ៖ ចុះអ្នកផ្សេងទៀត អ្នកណាអ្នកដឹកនាំធំ?

ឈាន ៖ អត់ស្គាល់គេទេ កងផ្សេងៗគ្នា យើងមិនអាច ។

ធានី ៖ ៣អនុសេនាតូច វាស្មើអនុសេនាធំមួយ?

ឈាន ៖ បាទ!

ធានី ៖ ហើយមេអនុសេនាធំនឹងឈ្មោះអីគេ?

ឈាន ៖ អានេះជាកងពិសេសរបស់តំបន់ ។

ធានី ៖ អ្នកណាគេប្រធានកងពិសេស?

ឈាន ៖ មានមេកងគេនឹង ខ្ញុំមិនស្គាល់ ភ្លេចបាត់ទៅ តាំងពីយូរឆ្នាំហើយ ចាំមិនបាន ។

ធានី ៖ បន្ទាប់មកទៀតម៉េចទៀតនៅភ្នំបាសិតនឹង?

ឈាន ៖ រហូត ខ្ញុំនៅជាទាហាននឹង ខ្ញុំឈរជើងនៅនឹងជាប់រហូតយើងធ្វើសង្គ្រាមវាមានការលំបាកវេទនាវេរជាប់គ្នាចុះឡើងរហូតដល់មានសន្តិភាពមកក៏ខ្ញុំមកនៅធ្វើស្រែនៅនេះ ។ អានឹងឈប់ធ្វើសង្គ្រាមហើយ ។

ធានី ៖ សង្គ្រាមពីឆ្នាំ៧៣ដល់ប៉ុន្មាន?

ឈាន ៖ ពីឆ្នាំ៧០រហូតដល់៧៥ ។

ធានី ៖ ចុះ៧៣ពូធ្វើទាហាននៅភ្នំពេញវិញ?

ឈាន ៖ ហ្នឹងហើយសង្គ្រាមនឹងកើតតាំងពីឆ្នាំ៧០ ដែលខ្ញុំចូលធ្វើទាហានឆ្នាំ៧៣ រហូតដល់៧៥ហ្នឹង កាលគេប្រវត្តិខ្មែរក្រហម ដែលយកជ័យជំនះថ្ងៃ១៧មេសានឹង ក៏ចប់សព្វគ្រប់ទៅក៏ខ្ញុំទៅធ្វើស្រែនៅនឹង ម៉ាដូវបាត់ជីងភ្នំបាសិត ។

ធានី ៖ ចេញពីទាហានមកធ្វើស្រែទៀត?

ឈាន ៖ បាទ! ហើយខ្ញុំនៅរហូតដល់សម័យមានសង្គ្រាមសារថ្មីទៀតរវាងវៀតណាម-កម្ពុជានឹង ក៏ខ្ញុំរត់តាមគេមកទៀតមក៧៩ ។

ធានី ៖ កាលពេលពូនៅនៅ៧៥នឹងធ្វើតែស្រែ អត់មានធ្វើអីទៀតទេ?

ឈាន ៖ អត់មានធ្វើអីទៀតទេ ។

ធានី ៖ តែពូម្នាក់ឯង?

ឈាន ៖ នៅជាមួយគេ ជាមួយឯង ។

ធានី ៖ ជាមួយអ្នកណាគេខ្លះ?

ឈាន ៖ ជាមួយពួកមិត្តៗយើង ។

ធានី ៖ មិត្តៗយើងខាងណាវិញ?

ឈាន ៖ ពួកទាហាន ខ្លះគេទៅបែកគ្នាឆ្ងាយទៅ ខ្លះក៏ខ្ញុំមកនៅជាមួយមីងៗ ។

ធានី ៖ មីងៗខាងណា?

ឈាន ៖ មីងៗនៅក្នុងភូមិគេនេះ ។

ធានី ៖ គេហៅអីគេកន្លែងនឹង?

ឈាន ៖ នៃក! បាត់ដឹង ។

ធានី ៖ គេហៅជាសហករណ៍អីគេ?

ឈាន ៖ គេហៅជាសហករណ៍អីទេភ្លេចហើយ ខ្ញុំមិនទាន់ធំណាស់ណាទេ ។

ធានី ៖ ការងាររបស់ពូធ្វើតែស្រែទេ អត់មានធ្វើអីទៀតទេ?

ឈាន ៖ បាទ! អត់មានធ្វើអីទៀតទេ ។

ធានី ៖ ចុះក្រៅពីនឹងទៀត មានធ្វើអីផ្សេងទៀតទេ?

ឈាន ៖ អត់ ។

ធានី ៖ អត់មានធ្វើអីសោះ?

ឈាន ៖ អត់ ។

ធានី ៖ ចុះមានដឹងរឿងសង្គ្រាមរវាងសម័យខ្មែរក្រហមជាមួយវៀតណាម?

ឈាន ៖ ចុះឃើញកាប់សម្លាប់ពីមុនៗវៀតណាមចូលមានកាប់សម្លាប់ចុះឡើងៗ ប៉ុនខ្ញុំអត់ដែលហ៊ាន ទៅរវីរវល់នឹងគេទេ ។

ធានី ៖ តែដឹង?

ឈាន ៖ ដឹងៗ ត្រឹមតែម៉ាឃើញ ត្រឹមតែម៉ាដឹង តែយើងកុំមាត់ យើងស្ងៀមខំធ្វើការងារខ្លួនយើង ហើយធ្វើអីកុំឲ្យគេចាប់អារម្មណ៍កុំឲ្យខុសបានរស់នៅបានយូរ ។

ធានី ៖ កាលពេលពូនៅបាសិតនឹង មានដឹងថានៅកន្លែងនឹង មានមន្ទីរសន្តិសុខ?

ឈាន ៖ ពិបាកដែរ គេមិនសូវឲ្យដឹង ។

ធានី ៖ តែពូបានដឹងរឿងនឹង ព្រោះពូនៅបាសិតធ្វើទាហាននៅមិនដឹងរឿង?

ឈាន ៖ ទេ! ក្រោយមកកាលនឹងទាហានអត់មានទេ ។ តែក្រោយមកយើងចប់សង្គ្រាមហើយ គេរៀបអីយ៉ាងម៉េច អានឹងដោយខ្លែកៗរៀងខ្លួន អានឹងយើងអត់ហ៊ាន ។ ត្រង់ណាយើងគួរធ្វើ ត្រង់ណាមិនគួរធ្វើ យើងកុំមាត់ នៅស្ងៀមខ្លួនយើងខាចរហូតមកទល់សង្គ្រាមវៀតណាមទៀត បានខ្ញុំថយចេញ រត់តាមគេតាមឯង៧៩ ។ ខ្ញុំរត់មករហូតដល់ព្រំដែនមកនៅម៉ាឡៃ ។

ធានី ៖ ពេលរត់មកដល់ដំបូងម៉េចដែរ ឃើញទិដ្ឋភាពម៉េច?

ឈាន ៖ វត់មកដំបូងវាព្រៃមែន សុទ្ធតែព្រៃទាំងអស់ ។

ធានី ៖ ពេលវត់ចេញពីភ្នំពេញមកវត់តាមអ្នកណាគេ អ្នកណាគេអ្នកដឹកនាំ ហើយម៉េចបានមកដល់នេះ?

ឈាន ៖ មិនដឹងអ្នកណាណែទេ ព្រោះវត់គ្នាច្រើនណាស់កាលនោះ ឃើញគេបាក់ចេះនាំគ្នាមកតាមគេតាមឯង ។ ប្រជាជនខ្លះក៏មានគោមានរទេះអីដឹកកូនចៅ ដឹកបាយ ឆ្នាំង ចានអីមក ៗ តាមគេតាមឯងមក ។ គេថាឲ្យវត់ៗ ហើយកើតសង្គ្រាមទៀតហើយក៏ចេញមក ខ្លះអីចាស់ៗក៏មកជាមួយបរទេះ ដើរផងអីផង ។

ធានី ៖ មានបររទេះដែរ?

ឈាន ៖ បររទេះគោយើងនឹង មកតាមហែលៗគ្នាមក ។ មកដល់នឹងគេរៀបចំចុះឡើងនៅនឹងគេទៅ ។

ធានី ៖ ដំបូងពេលពូវត់ទៅពីភ្នំពេញ ពូវត់ទៅកន្លែងណា បានមកដល់កន្លែងនេះ?

ឈាន ៖ វត់ចុះមកលិចមក តាមគេតាមឯង ។

ធានី ៖ អត់ដឹងកន្លែងណា ឃើញគេវត់ចេះវត់?

ឈាន ៖ បាទ! កាត់ព្រៃកាត់អីមក ។

ធានី ៖ ពូមានចាំថា វត់កាត់ភូមិស្រុកណាខ្លះ?

ឈាន ៖ វត់កាត់តាមជ្រលងគួយនេះ ។

ធានី ៖ ជ្រលងអីគេ?

ឈាន ៖ ជ្រលងគួយ ស្ទឹងជ្រលងគួយ សំឡូតយើងនេះ ។

ធានី ៖ ហើយពីណាមកទៀត?

ឈាន ៖ កាត់មកប៉ៃលិនមក ។

ធានី ៖ វត់ចេញពីភ្នំពេញទៅបាសិត?

ឈាន ៖ ខ្ញុំមិននៅភ្នំពេញទេ ខ្ញុំនៅបាត់ដំបងក្រោយនេះ ។ ហើយដល់ពេលមានអីចឹងមក ក៏ខ្ញុំវត់តាមគេតាមឯងមករហូតកាត់សំឡូត ស្ទឹងជ្រលងគួយចូលមកសំឡូត ចេញមកធ្លាក់នៅសាលាក្រៅកំរៀង ។

ធានី ៖ ហើយទៅណា?

ឈាន ៖ ហើយមកនេះ ។

ធានី ៖ ពូវត់រហូតអត់មាននៅមួយកន្លែងសិន?

ឈាន ៖ អត់ទេ អត់មាននៅទេ ម៉ារយៈដើររហូត ព្រឹកឡើង គឺថាពេលយប់នាំគ្នាសម្រាកទៅ តែយើងមើលអីមិនឃើញ វាព្រៃខ្លាំងពេក ព្រឹកឡើងចេះតាមគេតាមឯងមក ។

ធានី ៖ ហើយពូដឹងថាមានអ្នកណាគេស្គាល់ផ្លូវអីទេ បានគេនាំមក?

ឈាន ៖ មាន ខ្ញុំដឹង គេប្រាប់ថាមានគេប្រាប់អ្នកនាំផ្លូវ តែខ្ញុំមិនស្គាល់ទេ គេអ្នកមេព្រៃ គេអ្នកនៅស្រុកភូមិ គេអ្នកនៅតំបន់ហ្នឹងហើយ គេដឹងផ្លូវណាគេរត់មកចេះមកៗរាប់រយរាប់ពាន់នាក់ទៅ ។

ធានី ៖ ហើយអ្នកនាំផ្លូវម្នាក់នឹង ពូអត់ស្គាល់ឈ្មោះគាត់ទេ?

ឈាន ៖ អត់ទេ អត់ដែលឃើញ អត់ដែលស្គាល់ ។

ធានី ៖ មិនមែនអ្នកនៅស្រុកយើង គាត់មកនៅនេះដែរអត់ទេ?

ឈាន ៖ អត់ដឹង រហូតមកក៏ខ្ញុំមិនដែលបានស្រាវជ្រាវអីគេ អត់ទេ ខ្ញុំថាមកដល់ជួបគេជួបឯងគគ្រឹកគគ្រេងបាននៅនឹងគេឯង ។

ធានី ៖ នៅម៉ាឡៃ?

ឈាន ៖ បាទ!

ធានី ៖ ពេលពូមកដល់កន្លែងនេះ បាននៅត្រឹងម៉ាកន្លែង អត់ទាន់ទៅណាទៀតទេ?

ឈាន ៖ បាទ!

ធានី ៖ ដែលថានៅប៉ុន្មានខែ?

ឈាន ៖ នៅរយៈកន្លះខែ ។

ធានី ៖ កាលពេលពូនៅកន្លះខែ ពូនៅយ៉ាងម៉េច ស្នាក់នៅបណ្ដោះអាសន្នសិន ឬយ៉ាងម៉េច?

ឈាន ៖ នៅបណ្ដោះអាសន្ន មានកាលនោះពួថាខាងខ្មែរក្រហមគេទាក់ទងអង្ករអីហូបបានពីថៃ បានរស់នៅបានរហូតទៅខ្ញុំទៅនោះ ព្រោះកាលនោះខ្ញុំរត់ដាច់អង្ករដាច់ស្បៀនច្រើនរាប់ច្រើន ។

ធានី ៖ យ៉ាងម៉េចទៅដាច់អង្ករដាច់ស្បៀង?

ឈាន ៖ ចុះអត់មានអង្កររហូបណា រត់កាត់ព្រៃមកទាំងអស់ ។ ដល់ក្រោយមកបានមានអង្កររមានអីហូបក្រោយមកបាននៅ១០២ដាប់នៅម៉ាឡៃដាប់ ។

ធានី ៖ កាលពេលដំបូងពូដឹងថា មានគេទាក់ទងរកស្បៀងរកអីហើយ ។ ពេលពូមកដល់ដំបូងនៅម៉ាឡៃពូថាព្រៃក្រាស មានគ្រុនចាញ់?

ឈាន ៖ គ្រុនចាញ់ក៏មាន ។

ធានី ៖ ហើយអត់ហូបម៉េច ពូនិយាយមិញ អត់ហូបយ៉ាងម៉េច?

ឈាន ៖ អត់មានម្ហូប អត់មានស្រូវមានអង្កររមានអីហូបទេ អត់មានទេ ។

ធានី ៖ ហើយប៉ុន្មាននាក់ដែលរត់មកជាមួយពូ ពេលនឹង?

ឈាន ៖ ច្រើនៗណាស់ ស្រីប្រុសមនុស្សចាស់ តាៗយាយៗមានទាំងអស់ កូនក្មេងតូចៗខ្លះក៏គ្នាឈឺស្លាប់ទៅតាមព្រៃគ្មានអីហូប សូម្បីតែមនុស្សធំនឹងក៏ស្លាប់ដូចគ្នា ។ អ្នកណាដែលមានកម្លាំងចេះដើរទៅៗ អ្នកណាអត់កម្លាំងដើរមិនរួចក៏ស្លាប់ទៅ អត់មានអីហូបអន្តរដាំបាយ ។

ធានី ៖ ច្រើននាក់ទេ ដែលពូមើលមកតាមផ្លូវ?

ឈាន ៖ វេទនាយាប់លំបាក ។ ដល់ក្រោយសមាហរណកម្មមក វាស្រួលបួល ។

ធានី ៖ តែការរត់មកដល់នេះវាលំបាកយ៉ាងម៉េច ពូអាចរៀបរាប់?

ឈាន ៖ ចុះបើគ្មានផ្ទះសម្បែង នាំគ្នាដេកតាមដី តាមព្រៃ សូម្បីតែទឹកក៏គ្មានហូបផង អត់មានអីហូបទេ ។ ដល់ក្រោយមកខាង កាលនឹងបើយើងនិយាយទៅរត់តាមខ្មែរក្រហម មកខាងគេក៏ទាក់ទងឲ្យនេះដែរ គេរៀបចំទាក់ទងពីណាពីណែមកនេះបានស្រួវបានអង្ករ ។

ធានី ៖ ពេលនឹងពូបានហូបដែរ?

ឈាន ៖ ហូប ។

ធានី ៖ ពូមានឈឺមានអីទេ?

ឈាន ៖ មានឈឺ ដាក់សារ៉ូដាក់អីក៏ជាទៅ ។

ធានី ៖ កាលដំបូង ដែលមកដល់នឹង?

ឈាន ៖ បាទ!

ធានី ៖ គ្រុនចាញ់ដែរអត់ទេ?

ឈាន ៖ គ្រុនចាញ់ក៏មាន ។

ធានី ៖ ពូឈឺគ្រុនចាញ់ដែរ?

ឈាន ៖ បាទ! ខ្ញុំគ្រុនចាញ់ ។

ធានី ៖ ពេលមកដល់នេះហើយបានឈឺ ឬមួយតាំងពីមុនមក?

ឈាន ៖ អត់ទេ ឈឺតាមផ្លូវមក តែវាមិនទាន់មានអី វាមិនទាន់ខ្លាំង ស្រាប់តែមកដល់នេះវាខ្លាំងបានមានថ្នាំគេព្យាបាល ។

ធានី ៖ បានមានខាងគេមកជួយ?

ឈាន ៖ បាទ!

ធានី ៖ ខាងណាគេមកជួយ?

ឈាន ៖ មេខ្មែរក្រហមនឹង ខាងតាៗខ្ញុំពួកតាប៉ុលពតអីៗនឹង ដែលមកជួយ ។

ធានី ៖ ដែលមកជួយប៉ុន្មាននាក់ទៅ?

ឈាន ៖ មិនដឹងប៉ុន្មាននាក់ខ្ញុំពុកតែឈ្មោះគេ គេមិនដឹងថាម៉េច គេទាក់ទងរៀបចំអង្ករឲ្យហូប ។

ធានី ៖ នៅឆ្នាំ៧៩នឹង?

ឈាន ៖ បាទ!

ធានី ៖ ហើយបន្ទាប់មកទៀតគេឲ្យអន្តរអីហើយ ម៉េចបានពូទៅនៅដងរ៉ែក?

ឈាន ៖ ហ្នឹងគេនាំយកទៅនឹង ។

ធានី ៖ ខាងណានាំ?

ឈាន ៖ មេៗខាងនឹង ។

ធានី ៖ នាំទៅណាវិញ?

ឈាន ៖ ទៅនៅនោះ ទៅនៅដងរ៉ែក ព្រោះនៅនេះវាព្រៃ ខាងនេះព្រៃច្រើន ។

ធានី ៖ យើងទៅទាំងអស់គ្នា ឬទៅតែពូទេ?

ឈាន ៖ ទៅជាកងៗ ។

ធានី ៖ តែមានអ្នកនៅនេះទេ?

ឈាន ៖ មាន ។

ធានី ៖ មានគេនៅនេះផង?

ឈាន ៖ បាទ! តាមការពារព្រំដែន ។

ធានី ៖ ប្រហែលប៉ុន្មាននាក់គេនៅនេះ ហើយប៉ុន្មាននាក់គេទៅភ្នំដងរ៉ែក?

ឈាន ៖ ខ្ញុំប៉ាន់ស្មានមិនត្រូវ ។

ធានី ៖ ហើយកាលនឹងមានមេដឹកនាំហើយ នៅជាកង?

ឈាន ៖ បាទ! នៅជាកង ។

ធានី ៖ អ្នកណាគេអ្នកដឹកនាំពូ?

ឈាន ៖ វាភ្លេចអស់ហើយ វាច្រើនណាស់ វាតាមដំណាក់ វាច្រើនលំបាក ។

ធានី ៖ និយាយពីអ្នកដែលនៅជិតស្និតរបស់ពូ មេកង?

ឈាន ៖ អានឹងដូចខ្ញុំនិយាយពីនោះមកអានឹងវាអ្នកផ្សេង ដល់ពេលយើងរត់មកគេផុតគេផុតឯងមក ដល់នេះមករហូតមក អានឹងវាមានផ្សេង ។

ធានី ៖ ផ្សេងអ្នកណាគេទៅ ពូចាំឈ្មោះគាត់?

ឈាន ៖ ខ្ញុំទៅនេះជាមួយបងដឹម ។

ធានី ៖ ដឹមនឹងអ្នកណាគេ?

ឈាន ៖ គាត់មេខ្ញុំ ។

ធានី ៖ មេងាររគាត់ជាអីគេ?

ឈាន ៖ មេកងខ្ញុំ ប៉ុនគាត់ពិការជើង ប៉ុនខាងប្រជាជន មិនមែនជាទាហានអីទេ ខ្ញុំទៅនៅជាមួយគេហើយ ។

ធានី ៖ កាលពេលនឹងពូពិការជើងហើយ ឬក៏?

ឈាន ៖ នៅទេ ។

ធានី ៖ ប៉ុន្តែមេកងរបស់ពូអ្នកពិការជើង?

ឈាន ៖ បាទ! អ្នកពិការជើង មិនមែនពិការដាច់ទេ គាត់ខ្វើចជើង គាត់ខូចជើងពីកំណើតនៅជាមួយគាត់ ។

ធានី ៖ ម៉េចបានពូសម្រេចចិត្តទៅនៅជងវែក?

ឈាន ៖ ចុះបើគាត់ទៅ ដល់នេះគាត់នាំទៅនៅរស់នៅដូចជាឪពុកម្តាយ ខ្ញុំនៅជាមួយគាត់អីចឹង ។

ធានី ៖ ប៉ុន្មាននាក់ដែលទៅជាមួយពូ?

ឈាន ៖ គ្នាច្រើនណាស់ ប្រហែលជាទាំងស្រីទាំងប្រុសកូនក្មេងស្រីប្រុសប្រហែល១០០នាក់ជាង ។

ធានី ៖ ស្រីប្រុសក្មេង គាត់មកពីណាវិញ?

ឈាន ៖ រត់មកជាមួយគ្នា ។

ធានី ៖ ដឹងថាគាត់នឹងជាអ្នកណាមកពីណាកាលពីមុន?

ឈាន ៖ អត់ដឹងទេ ។

ធានី ៖ អត់បានសួរគេ?

ឈាន ៖ អត់បានសួរទេ ។ ជារួមដូចយើងរាប់អ្នកទទួលខុសត្រូវ ជាមេ ព្រោះគាត់អ្នកចាស់ជាងគេ គាត់ចេះប្រមូលគ្នា ជួយមើលគ្នាទៅ នាំទៅ ។

ធានី ៖ ពូទៅនៅជងវែកនៅធ្វើអីគេ?

ឈាន ៖ ទៅនៅជាប្រជាជនដែរ ។

ធានី ៖ ធ្វើអីគេ?

ឈាន ៖ នៅដាំដំណាំហូប ដាំស្រូវហូប ។

ធានី ៖ ចុះកាលនឹងពូទៅដល់នឹងមានស្បៀងហូបហើយ?

ឈាន ៖ មានហើយ ដាំហែកៗបាន ដាំបន្លែដាំអីបានហើយ ។

ធានី ៖ មិនមែននៅជំរុំទេ នៅតាមព្រំដែន?

ឈាន ៖ អត់ទេ យើងនៅតាមនេះធម្មតា នៅតាមព្រំដែនធម្មតា ប៉ុនយើងនៅលើភ្នំជាប់ព្រំដែន អានឹងគេដាំដំណាំបាន ព្រោះដីយើងវាស្រឡះវាមិនព្រៃដូចនៅនេះ វាស្រឡះវាកាប់ឆ្ការតិចៗទៅយើងដាំបាន ។

ធានី ៖ នៅលើភ្នំស្រឡះជាង មិនដូចនៅនេះព្រៃវាយ៉ាងម៉េច ខុសគ្នា?

ឈាន ៖ បាទៗ នេះព្រៃខ្លាំងមែនទែន ព្រៃចូកអត់ចង់ចុះ បើនោះគេស្រឡះ ហើយតំបន់នេះវាចាញ់ជាងនោះ ។ នោះអត់មានអីទេ ។

ធានី ៖ អ្នកនៅនេះ អ្នកខ្លះគេនៅនេះ ដល់ពេលពួទៅនៅនោះ?

ឈាន ៖ បាទ! ខ្ញុំទៅនោះ ខ្ញុំប្រជាជន ។

ធានី ៖ អ្នកនៅនេះមិនមែនប្រជាជនទេ?

ឈាន ៖ មានប្រជាជនខ្លះដែរ ។

ធានី ៖ មានខ្លះដែរ?

ឈាន ៖ បាទ! ដូចថាអ្នកមកដល់មុននៅមុនទៅ អ្នកមកនៅក្រោយក៏នៅក្រោយទៅ ។

ធានី ៖ ពូថាទៅដងរែកនៅឆ្នាំ៧៩ ម៉េចបានពូត្រឡប់មកម៉ាឡៃ?

ឈាន ៖ អានឹងគេចូលរៀបចំ គេជ្រើសរើសក្នុងជួរសម័យខ្មែរក្រហមនឹង គេជ្រើសរើសកម្លាំងទ័ព ឲ្យខ្ញុំវិលមកនេះវិញ ។

ធានី ៖ ជ្រើសរើសកម្លាំងទ័ពធ្វើអី?

ឈាន ៖ កម្លាំងទ័ពវៃគ្នាជាមួយវៀតណាម ព្រោះផ្នែកខាងលិចនេះដឹកនាំដោយខ្មែរក្រហម តែមេណាៗខ្ញុំមិនស្គាល់ច្បាស់លាស់ទេ ។

ធានី ៖ ចុះនៅដងរែក?

ឈាន ៖ ដងរែកក៏ដូចគ្នា ។ ប៉ុនកាលនោះ ខ្ញុំជាប្រជាជន ។

ធានី ៖ ចុះប្រជាជន ពូអត់ដឹងថាអ្នកណាដឹកនាំទេ?

ឈាន ៖ ប្រជាជននៅក្នុងរបបខ្មែរក្រហមដូចគ្នា ។

ធានី ៖ អ្នកណាគេអ្នកដឹកនាំ?

ឈាន ៖ យាយថែម ។

ធានី ៖ អីគេថែម?

ឈាន ៖ អត់ស្គាល់ទេ មិនដឹងនាមត្រកូលគេម៉េច ។

ធានី ៖ នៅដងរែកនឹង យាយថែម?

ឈាន ៖ បាទ!

ធានី ៖ យាយថែមនឹងអ្នកដឹកនាំពូ?

ឈាន ៖ បាទ! ប៉ុនអានឹងជាមេធំដូចថាគេទទួលខុសត្រូវធំ គេទទួលខុសត្រូវធំ ប៉ុនក្រោមៗទៀតមានណាណែទៀតច្រើន ខ្ញុំចាំមិនបាន ។

ធានី ៖ យាយថែមនឹង គាត់អ្នកដឹកនាំអីគេ?

ឈាន ៖ ដឹកនាំប្រជាជន គ្រប់គ្រងប្រជាជន ។

ធានី ៖ ដឹកនាំប្រជាជនយ៉ាងម៉េច?

ឈាន ៖ រៀបចំធ្វើចំការ ដាំបន្លែអីហូបនៅនឹង ។ ដល់ឆ្នាំ៨២បានខ្ញុំចេញមកនេះ ។

ធានី ៖ ដល់ឆ្នាំ៨២ គេរើសទាហាន ពូត្រឡប់មកម៉ាឡៃ?

ឈាន ៖ បាទ!

ធានី ៖ ក្រៅពីយាយថែមមានអ្នកណាគេទៀត ពូចាំទេ?

ឈាន ៖ អត់មានទេ មានមេៗច្រើនទៀត ប៉ុនខ្ញុំមិនស្គាល់ៗខ្ញុំត្រឹមប្រជាជន ។

ធានី ៖ ដល់ពូមកម៉ាឡៃវិញ អ្នកណាគេអ្នកគ្រប់គ្រងពូ?

ឈាន ៖ មានម្នាក់នឹងមានលោកសុខ ភាពសព្វថ្ងៃ ។

ធានី ៖ គាត់អ្នកគ្រប់គ្រងពូ?

ឈាន ៖ បាទ! ម៉ាកងពលនៅនឹង ។

ធានី ៖ កាលនឹងពូវ៉ៃនៅកន្លែងណាខ្លះទៅ នៅម៉ាឡៃនឹង?

ឈាន ៖ ខ្ញុំនៅខាងក្រោយទេ អត់មានបានទៅណាទេ ។

ធានី ៖ ខាងក្រោយនឹងធ្វើអីគេ?

ឈាន ៖ ដូចថាយើងនៅមើលប្រជាជន ការពារប្រជាជនខាងក្រោយ ហៅថាការពារមូលដ្ឋាននៅប្រតិបត្តការណ៍ខាងក្រោយការពារមូលដ្ឋាន រហូតដល់ខ្ញុំពិការជើង ។

ធានី ៖ កាលពេលពូការពារមូលដ្ឋាននៅ ការពារកន្លែងណា?

ឈាន ៖ ការពារនៅស្រុកម៉ាឡៃ ។

ធានី ៖ ម្តុំណា?

ឈាន ៖ តាមនឹង តាមសមរភូមិខាងមុខ ម៉ាជួរហុងទឹក ប៉ុនកាលនោះសុទ្ធតែព្រៃទេ អត់មានស្រឡះដូចសព្វថ្ងៃនេះទេ ។ ព្រោះពីដើម្បីសុទ្ធតែព្រៃឈើធំៗ ដូចខ្ញុំនិយាយពីដើមថាអត់មានសាលារៀន ផ្ទះសំបូរច្រើនដូចចេះទេ ច្រើនតែព្រៃ ។ ហើយផ្ទះដែលរស់នៅធ្វើកូនខ្ទមប្រក់ស្បូវតូចៗនៅទេធ្វើរានទៅទេ ព្រោះព្រៃច្រើន ហើយគ្រុនចាញ់វាច្រើន ហើយកន្លែងមន្ទីរពេទ្យតូចមួយទេ ដែលសម្រាប់ព្យាបាលជម្ងឺ ។

ធានី ៖ ខាងណាគេអ្នកមកព្យាបាល?

ឈាន ៖ ព្យាបាលមានតែមន្ទីរពេទ្យខ្មែរក្រហមនឹង ។

ធានី ៖ ស្គាល់ឈ្មោះគាត់ទេ ដូចថាអ្នកដឹកនាំនៅមន្ទីរពេទ្យនឹង ព្យាបាលអ្នកជម្ងឺនឹង?

ឈាន ៖ អ្នកជម្ងឺ យាយកេងរាល់ថ្ងៃ ។

ធានី ៖ ស្អីគេកេង?

ឈាន ៖ មិនដឹងស្អីគេកេងទេ ។

ប្រពន្ធ ៖ គាត់ផ្លាស់ឥឡូវស៊ីម៉ន ។

ធានី ៖ ឥឡូវគាត់ឈ្មោះស៊ីម៉ន?

ប្រពន្ធ ៖ ឃឹម ស៊ីម៉ន បើមិនឃឹម ស៊ុម ស៊ីម៉ន ។ ប៉ុនយើងពីដើមមកយើងហៅតែយាយកេងៗ តែដល់ឈ្មោះគាត់ពិតឃឹម ស៊ីម៉ន ។

ធានី ៖ ព្រោះកូនគាត់រាល់ថ្ងៃធ្វើប្រធានពេទ្យវិញ?

ប្រពន្ធ ៖ អាហុកនោះឈ្មោះស្អីត្រង់ណា យើងហៅសាមញ្ញ ដល់គេដាក់ឈ្មោះនឹងទៅវាចំម៉ាក្លែតៗ កូនប្រសារគាត់ប្រធានពេទ្យមណ្ឌល ។

ធានី ៖ ឃឹម ស៊ីម៉ន គាត់?

ប្រពន្ធ ៖ ឈ្មោះគាត់ ស៊ីម៉ន ហៅយាយកេង ។

ឈាន ៖ ខ្ញុំស្គាល់ឈ្មោះគាត់កាលពីមុន តែឥឡូវគេប្រែខ្ញុំអត់ស្គាល់ ។

ធានី ៖ អីចឹងភាគច្រើនអ្នកនៅនេះ គេប្រែឈ្មោះទាំងអស់?

ឈាន ៖ ពេលខ្លះគេប្រែគេអីខ្លួនគេ ។

ប្រពន្ធ ៖ ប៉ុនគ្រាន់ថាធ្វើការ ពេលណាគេមានកាលមុនគេហៅអីចឹង ដល់ពេលគាត់ធ្វើការធំអីចឹងគាត់ ដាក់ឈ្មោះ គាត់ដូរឈ្មោះខ្លួនគាត់ ។ ហើយហៅតែយាយកេងៗទៅ មានតែអ្នកធ្វើការ ដែលស្គាល់ ។

ធានី ៖ យាយកេងគេស្គាល់ច្រើនជាង?

ប្រពន្ធ ៖ យាយកេងគេស្គាល់ទូទៅ ។ ដូចលោកគ្រូអ៊ុច វ៉ន ជាទូទៅស្គាល់គ្រូវ៉ុងនោះ ប៉ុនគាត់ជាឈ្មោះ វ៉ាយ ចាន់រ៉ុង ឈ្មោះគាត់យើងហៅលោកគ្រូវ៉ន ។

ធានី ៖ លោកគ្រូអីគេ មិញមីងនិយាយ?

ប្រពន្ធ ៖ លោកគ្រូវ៉ន ។

ធានី ៖ គាត់ធ្វើមេភូមិ?

ប្រពន្ធ ៖ អត់ទេ គាត់នាយកសាលាពីមុន ឥឡូវគាត់Retiredហើយយើងស្គាល់លោកគ្រូវ៉ន ដល់ឈ្មោះ គាត់វ៉ាយ ចាន់រ៉ុង ។

ធានី ៖ ឈ្មោះនៅណា ក្នុងបញ្ជីជាតិនឹង?

ប្រពន្ធ ៖ វ៉ាយ ចាន់រ៉ុង ។

ធានី ៖ ដល់ឈ្មោះយើង?

ប្រពន្ធ ៖ ឈ្មោះ វ៉ន យើងមិនដឹងជាអ៊ីក ហើយអីទេ យើងស្គាល់តែវ៉ន។ ហើយដូចលោកគ្រូគូ យើងហៅលោកគ្រូគូ ប៉ុនគាត់នោះមិនមែនលោកគ្រូគូណា ឈ្មោះគាត់នេះ ឈ្មោះ ចាន់ថូ។

ធានី ៖ ពូនិយាយថា ពូនៅឆ្នាំ៨៥ ពូរត់ទៅព្រំដែន?

ឈាន ៖ បាទ! ខ្ញុំចេញនោះ ឆ្នាំ៨៥បានខ្ញុំមកនៅនេះ។

ធានី ៖ ប៉ុន្តែពូថា?

ឈាន ៖ អឺ! ឆ្នាំ៨៥ខ្ញុំទៅនៅថៃ។

ធានី ៖ ថៃរហូតដល់?

ឈាន ៖ នៅក្នុងជំរុំ។

ធានី ៖ម៉េចបានទៅនៅថៃ?

ឈាន ៖ ចុះកាលនោះយួនមិនវ៉ៃបែកតាមព្រំដែន វៀតណាមវ៉ៃបែកទាំងអស់របបខ្មែរក្រហមតាមព្រំដែន ខ្ញុំរត់ទៅនៅថៃ។

ធានី ៖ រត់ទាំងអស់គ្នា?

ឈាន ៖ ទាំងអស់គ្នា។

ធានី ៖ អ្នកនៅម៉ាឡៃប៉ុន្មានទាំងប៉ុន្មានរត់ទាំងអស់?

ឈាន ៖ បាទ! រត់ទាំងអស់ទៅនៅជំរុំ។

ធានី ៖ ពូដឹងថាដំបូងឡើងអ្នកចងក្រងធ្វើជាទ័ពដូចពូនិយាយមិញ អ្នកណាអ្នកផ្តួចផ្តើមគំនិត?

ឈាន ៖ ដឹងម៉េច ខ្ញុំដឹងថានៅជាមួយលោក សុខ ភាព។

ធានី ៖ ដឹងថាលោកសុខ ភាព គាត់អ្នកមេធំ គ្រប់គ្រងខាងនៅនឹង?

ឈាន ៖ ខាងទាហាន។

ធានី ៖ ដល់ពេលប្រជាជន?

ឈាន ៖ ប្រជាជនមានពីណា មានអ៊ីយ៉ែម។

ធានី ៖ អ៊ីគេយ៉ែម?

ឈាន ៖ ខ្ញុំអត់ស្គាល់ទេ។

ធានី ៖ អ៊ីយ៉ែមខាងប្រជាជន លោកសុខ ភាពខាងកងទ័ព?

ឈាន ៖ ហៅអ៊ីយ៉ែមៗ។

ធានី ៖ ចុះលើលោក សុខ ភាពមានទៀតទេ?

ឈាន ៖ ដឹងអី ខ្ញុំដឹងតែកន្លែងនឹង ដឹងលោក សុខ ភាព ។

ធានី ៖ បន្ទាប់មកម៉េចទៀត ដល់ឆ្នាំ៨៥រត់ទៅថៃហើយ បានប៉ុន្មានបានមកវិញ?

ឈាន ៖ ហ្នឹងនែក! ៨៦ ៨៩ ចូលមកនៅនឹង ។

ធានី ៖ ម៉េចបានចូលមកនៅនឹង?

ឈាន ៖ ចុះដែលខ្មែរក្រហមវាវ៉ៃ ដែលយួនថយទៅ ខ្មែរក្រហមចូលមកតាមព្រំដែនវិញ បានកើតសមាហរណកម្ម ។

ធានី ៖ យួនថយ៣-៤ឆ្នាំ ក្រោយពេលវ៉ៃហើយ?

ឈាន ៖ បាទ! រហូតដល់សមាហរណកម្ម ។

ធានី ៖ ពេលពូចូលមកវិញ ម៉េចដែរ?

ឈាន ៖ សុទ្ធតែព្រៃទាំងអស់ ដូចខ្ញុំនិយាយ ។

ធានី ៖ ដូចមុនទេ?

ឈាន ៖ ដូចមុន ។

ធានី ៖ ហើយម៉េចទៀតទៅ?

ឈាន ៖ មានមីន កាលនឹងខ្ញុំគ្រោះថ្នាក់នឹង មីននៅតាមព្រំដែន ។

ធានី ៖ ចុះកាលពេលពូចូលមកដំបូងមានមីនអត់?

ឈាន ៖ មាន ។

ធានី ៖ ចូលមកម៉ាឡៃលើកដំបូងទៀត?

ឈាន ៖ បាទ! ចូលមកមានមីន សុទ្ធតែមីន ។

ធានី ៖ ខាងណាអ្នកណាដាក់?

ឈាន ៖ ខាងវៀតណាម ។ ខ្ញុំដឹងខាងវៀតណាម ។

ធានី ៖ កាលចូលមកឆ្នាំ៧៩?

ឈាន ៖ បាទ!

ធានី ៖ ហើយដល់ពេលក្រោយមកទៀត?

ឈាន ៖ ហ៎! ៧៩អី ឆ្នាំ ៨០គត់នេះ អាឆ្នាំដែលខ្ញុំចេញពី៨៥មកនឹង ។

ធានី ៖ កាលពេលពូចូលមកម៉ាឡៃដំបូងបំផុត ពេលដែលពូថានៅ៧៩ នៅបានកន្លះខែនឹង មានមីនអត់?

ឈាន ៖ អត់មានទេ ប៉ុនសុទ្ធតែព្រៃហើយ គ្រង់ណាក៏ព្រៃដែរ ។

ធានី ៖ តែអត់មានមីនទេ?

ឈាន ៖ អត់មានមីនទេ ។

ធានី ៖ ទើបមានពេលឆ្នាំ៨៥ នឹងទេ?

ឈាន ៖ បាទ!

ធានី ៖ ពេលដែលពូចូលមកលើកទី២ បានមានមីន?

ឈាន ៖ បាទ! បានមានមីន ។

ធានី ៖ មីននឹងខាងណាគេអ្នកដាក់?

ឈាន ៖ ខាងវៀតណាម ។

ធានី ៖ ខាងវៀតណាមតែម្យ៉ាងទេ?

ឈាន ៖ បាទ!

ធានី ៖ វៀតណាមអ្នកដាក់ទាំងអស់?

ឈាន ៖ មិនដឹងជាអ្នកណាៗ កាលនឹងសង្គ្រាមជាមួយវៀតណាម ។

ធានី ៖ ពូនៅព្រំដែនធ្វើអីខ្លះ នៅជំរុំនឹងអីគេ?

ឈាន ៖ នៅជំរុំ៨៥ នៅដីថៃ ប្រជាជនគេជម្លៀសទៅនៅនឹង ។

ធានី ៖ នៅនឹងធ្វើអីគេ?

ឈាន ៖ មានអីនៅធ្វើប្រជាជន ។

ធានី ៖ ម៉េចដែរការរស់នៅជំរុំ?

ឈាន ៖ នៅជំរុំយ៉ាប់ដែរ ចុះយើងនៅជំរុំ យើងគ្មានសិទ្ធិដើរហើរទៅណាមកណាអត់បាន យើងនៅមើលកូនចៅនៅជំរុំនឹង ។

ធានី ៖ ចុះមកដល់៨៩ នៅម៉ាឡៃ ចុះពូពិការជើងពេលណា?

ឈាន ៖ ពិការជើងពេលដែលខ្ញុំចេញមកពីនោះ ។

ធានី ៖ ពេលមកដល់ផ្ទះភ្លាម?

ឈាន ៖ មកដល់សុទ្ធតែព្រៃទាំងអស់ ព្រោះថាកាលនឹងវាងខ្មែរក្រហមនិងវៀតណាមនឹង គេចាញ់ដៃម្ខាងៗ គេយកប្រជាជនមកនៅតាមព្រំដែន ។ បានមកនៅតាមព្រំដែន ខ្ញុំពិការជើង វាមានមីនច្រើនពេញទឹកពេញដីច្រើន ។ ហើយពេលនឹងក៏ស្លាប់ច្រើនដែរ អ្នកគ្រោះថ្នាក់ ។

ធានី ៖ ប្រជាជនស្លាប់ច្រើន?

ឈាន ៖ បាទ! ប្រជាជនក៏ស្លាប់ច្រើន កូនក្មេងក៏ច្រើន វាឈឺច្រើន អត់មានថ្នាំ អត់មានអីទេ អត់មានមន្ទីរពេទ្យត្រឹមត្រូវ ។ ដល់ក្រោយមកបានរៀបចំមន្ទីរពេទ្យខាងខ្មែរក្រហមយើង ហើយក៏រស់នៅព្យាបាលទៅ រៀបចំផ្ទះសម្បែងធ្វើចំការធ្វើស្រែរហូត ។

ធានី ៖ បន្ទាប់មកទៀត ឆ្នាំប៉ុន្មានប្រាកដដែលពូពិការជើង?

ឈាន ៖ ខ្ញុំឆ្នាំ៩០គត់ ពិការជើងខែ១១ ។

ធានី ៖ អត់ដឹងកន្លែងនឹងមានមីន ហើយម៉េច?

ឈាន ៖ អត់ដឹង ។

ធានី ៖ ពេលពូមកមានគេគ្រប់គ្រងលើពូហើយ?

ឈាន ៖ មាន ។

ធានី ៖ អ្នកណាគេ?

ឈាន ៖ លោកសុខ ភាពខាងទ័ព ហើយអ៊ំយ៉ែមនឹងខាងប្រជាជន ។

ធានី ៖ ម៉េចគេគ្រប់គ្រងការរស់នៅ?

ឈាន ៖ ការរស់នៅមានអី មានអង្ករហូប មានខោអាវស្លៀកពាក់ត្រឹមត្រូវ ធម្មតាមានមន្ទីរពេទ្យអីគេជួយដែរ ប៉ុន្មមិនដូចពេលសព្វថ្ងៃនេះទេ ព្រោះការនោះដូចខ្ញុំជម្រាបអីចឹងថាវាព្រៃច្រើនណាស់ សុទ្ធតែព្រៃ ។

ធានី ៖ ចុះម៉េចបានវាលអស់?

ឈាន ៖ ចុះក្រោយសមាហរណកម្មយើងឈប់វៃគ្នាហើយ ប្រជាជនចេះថាវាលែងមានសង្គ្រាម ចេះនាំគ្នាកាប់ឆ្ការដាំដុះធ្វើផ្ទះ ធ្វើសម្បែងនៅ ។

ធានី ៖ អីចឹងមុនសមាហរណកម្មព្រៃសុទ្ធ?

ឈាន ៖ ព្រៃទាំងអស់អត់មានផ្ទះធំដុំ អត់មានអីស្រួលបួល សុទ្ធតែព្រៃទាំងអស់ពីមុន រហូតទាល់តែសមាហរណកម្មបានរៀបចំស្រួលបួល ។

ធានី ៖ ចុះចន្លោះ៩០ជាងអីមានគេប្រមូលរបស់ចូលសហករណ៍រួមមានទេ?

ឈាន ៖ អត់មានទេ ខ្ញុំអត់ដឹង ។

ធានី ៖ នៅធម្មតា យើងរស់នៅជាឯកជន?

ឈាន ៖ ព្រោះឯនោះមិនដឹង ប៉ុនអានេះអត់មាន ។

ធានី ៖ ឆ្នាំប៉ុន្មានសមាហរណកម្ម?

ឈាន ៖ ឆ្នាំអាច៩០គត់ ឬ៩១ ។

ធានី ៖ ក្រែងពូចូលមកនេះឆ្នាំប៉ុន្មាន?

ឈាន ៖ ៨៨ ៨៩ ៨៩ចុះ ។

ធានី ៖ ពេលណាធ្វើសមាហរណកម្ម?

ឈាន ៖ ៩៦មិនដឹង ៩១ ។

ធានី ៖ ៩៦ ឬ៩១?

ឈាន ៖ ៩១អាច៩១ ខែប៉ុន្មានខ្ញុំចាំអត់បានៗ ៩០មិនដឹង៩០ប៉ុន្មានៗ

ធានី ៖ សំខាន់ពូចាំថាពូមកនៅនេះបានប៉ុន្មានឆ្នាំ ដូចថាពេលនឹងកូនទីប៉ុន្មាន?

ឈាន ៖ មិនដឹង ខ្ញុំចាំមិនបាន អាចខ្ទង់ឆ្នាំ៩០នឹងហើយ ប៉ុនមិនដឹងឆ្នាំប៉ុន្មានៗ

ធានី ៖ កាលនឹងពូមានបានចូលរួមបោះឆ្នោតអ៊ុនតាក់អី?

ឈាន ៖ បោះឆ្នោតអ៊ុនតាក់អត់មានៗ បានគេខាងក្នុងៗ

ធានី ៖ តែយើងបានពូ?

ឈាន ៖ បាទ! ពូៗ

ធានី ៖ តែកាលនឹងអត់ទាន់ធ្វើសមាហរណកម្មទេ?

ឈាន ៖ បោះឆ្នោតអ៊ុនតាក់នៅទេ អត់ទាន់មានទេៗ

ធានី ៖ ប្រហែលចន្លោះបោះឆ្នោតអ៊ុនតាក់ប៉ុន្មានឆ្នាំ បានគេធ្វើសមាហរណកម្ម?

ឈាន ៖ ១ឆ្នាំជាង ប្រហែល២ឆ្នាំៗ

ធានី ៖ កាលនឹងពូមានកូនទីប៉ុន្មានហើយ?

ឈាន ៖ កូនធំៗ ៗ

ធានី ៖ គាត់កើតពេលណា?

ឈាន ៖ កើត៩២ ៗ

ធានី ៖ សមាហរណកម្មពេលណា បានគាត់អាយុប៉ុន្មានចាំទេ?

ឈាន ៖ អាច៩៦ ៗ

ធានី ៖ ពូអត់ចាំទេ?

ឈាន ៖ អត់ចាំៗ

ធានី ៖ ក្រោយពីសមាហរណកម្មមក យ៉ាំងម៉េចដែរការរស់នៅរបស់ពូ?

ឈាន ៖ មានអី រៀបចំលួរហូតតាំងពីនឹងមក អត់មានបញ្ហាអីៗ

ធានី ៖ រៀបចំល្អម៉េច? កាលនឹងផ្ទះពូនៅខាងណាខាងណៃ?

ឈាន ៖ មុនដំបូងខ្ញុំនៅនោះទេ នៅជាប់ព្រំដែនមាត់អូរព្រំដែន ដល់ក្រោយមកកាប់ឆ្ការដីរៀបចំឲ្យស្រួលបួល ខ្ញុំចេញមកនៅវាលនេះៗ

ធានី ៖ កាប់ឆ្ការដីនឹងគេគិតម៉េចដែរ?

ឈាន ៖ អានឹងអ្នកណាគេឆ្ការបានយើងយកទៅ យើងមានកម្លាំងធ្វើបានយើងយកទៅ ព្រោះគេមិនហួងទេកាលនោះៗ

ធានី ៖ អ្នកណាគ្នារ អ្នកនឹងយក ពូថាកាលនឹងមានមីន?

ឈាន ៖ មានៗ ចេះខំរកទៅ ខំធ្វើទៅ បើយើងមិនខំរក មានបានអី កាលនឹងគេគ្រាន់ឲ្យយើងធ្វើចំការ ខ្លួនយើង ហើយខំរកខ្លួនឯង មកទល់សព្វថ្ងៃបានរៀបចំភូមិ ។

ធានី ៖ ពូមានដីចំការបានប៉ុន្មាន?

ឈាន ៖ ខ្ញុំមានដីចំការបាន៣០ រ៉ៃ ។

ធានី ៖ ពូរៀបគ្រួសារពេលណា?

ឈាន ៖ ខ្ញុំយកគ្រួសារតាំងពី៧៦ ។

ធានី ៖ ចិត្តពូចង់ខ្លួនឯង ឬមួយមានគេរៀបឲ្យ?

ឈាន ៖ យកខ្លួនឯង ។

ធានី ៖ រៀបនៅណា?

ឈាន ៖ ខ្ញុំរៀបម៉ាជួរបាត់ដឹង ។

ធានី ៖ ពេញចិត្តគ្នាទៅវិញទៅមក?

ឈាន ៖ អត់ទេ គ្មានអ្នកណាគេបង្ខំ ។

ធានី ៖ រៀបការតាមប្រពៃណីយើង ឬម៉េច?

ឈាន ៖ អត់ទេ រៀបដូចគេរៀបសម័យនឹងគេគ្រាន់ហៅមកគេសួរយើងស្រឡាញ់គ្នាស្រួលបួលត្រឹម ត្រូវយើងមិនមានអី អានឹងគេឲ្យយកទៅ ។

ធានី ៖ តែប៉ុននឹង?

ឈាន ៖ បាទ!

ធានី ៖ ខាងណាជួយរៀបឲ្យពូ?

ឈាន ៖ មេៗ ។

ធានី ៖ ស្គាល់ឈ្មោះគាត់គេ?

ឈាន ៖ មេភូមិគេឈ្មោះ មី ឈ្មោះ ខាំ មី ។

ធានី ៖ ខាំ មីនឹងមកពីណាវិញ?

ឈាន ៖ នៅជាមួយខ្ញុំ មេនៅជាមួយគ្នា ប៉ុនស្រុកភូមិយើងមិនដឹងនៅណាទេ ព្រោះសម័យនោះ ។

ធានី ៖ តែគាត់ជាខ្មែរយើង?

ឈាន ៖ ខ្មែរយើង ។

ធានី ៖ និយាយធម្មតា?

ឈាន ៖ បាទ!និយាយដូចគ្នា ។

ធានី ៖ តែឈ្មោះ មិនមែនដូចខ្មែរ?

ឈាន ៖ មិនដឹងអី ប៉ុនសំបុរស ប៉ុនគេនិយាយខែរច្បាស់ នៅព្រះវិហារ អាចជនជាតិ ។

ធានី ៖ ហើយរាល់ថ្ងៃគាត់នៅយើង?

ឈាន ៖ អត់ដឹងទេ បែកបាក់គ្នាក្រោយមក ។

ធានី ៖ ដល់ពេលពូរត់ ពូរត់តាមមេដែរ?

ឈាន ៖ វាគ្នាច្រើនរត់បែកបាក់គ្នា ។

ធានី ៖ ចុះគ្រួសារពូមកតាមគ្នារហូតដែរ?

ឈាន ៖ មកតាមរហូត ។

ធានី ៖ ដែលធ្លាប់មកលេងស្រុកទេ មកដល់សព្វថ្ងៃ?

ឈាន ៖ ទៅលេង ។

ធានី ៖ ទៅលេងញឹកញាប់?

ឈាន ៖ ទៅលេងកាលម្ដាយខ្ញុំនៅរស់ ហើយគាត់ខូច គាត់ស្លាប់ ។

ធានី ៖ ហើយទៅលេងនឹង មានអារម្មណ៍ម៉េចដែរ?

ឈាន ៖ មានអីធម្មតា គាត់ស្រណោះកូនដែលបែកបាក់គ្នា ។ នឹកកូន នឹកអីយើងមកលេង ។

ធានី ៖ ចុះបងប្អូនពូនៅស្រុកកំណើតដែរ?

ឈាន ៖ នៅៗសព្វថ្ងៃ ។

ធានី ៖ ដែលទៅលេងគាត់ទេ?

ឈាន ៖ ទៅលេង ប៉ុនខាន២ឆ្នាំខ្ញុំអត់បានទៅលេង គ្មានលុយគ្មានកាក់ឆ្ងាយណាស់ យើងទម្រាំទៅដល់ ម្យ៉ាងជាប់ចិញ្ចឹមកូន ។

ធានី ៖ ក្នុងជីវិតពូ ពូគិតថាការរស់នៅពីមុនហើយឥឡូវវាដូចគ្នា ឬខុសគ្នា តើវាខុសគ្នាយ៉ាងម៉េច ដូចគ្នាយ៉ាងម៉េច?

ឈាន ៖ វាខុសគ្នាដែរ ពីមុននិយាយរួមដូចខ្ញុំនិយាយពីដើម វាលំបាកណាស់ តែសព្វថ្ងៃវាដូចថាយើងមានជីវភាពធូរក្នុងគ្រួសារ ។ ម្យ៉ាងដែរយើងធ្វើស្រែចំការបាន ប៉ុនវាពិបាកត្រង់ថាសេដ្ឋកិច្ច ដូចថាផលដំណាំធ្វើបានទិញពីផ្សារមក យើងលក់ទៅបានថោក ។

ធានី ៖ តាំងពីមុនហើយឥឡូវមួយណា ពូគិតថាមួយណាស្រួលរស់នៅជាងសម្រាប់ចិត្តពូ?

ឈាន ៖ អត់ទេ ពីមុនផ្សេង ឥឡូវវាផ្សេង រស់នៅឥឡូវវាស្រួលជាងពីមុនឆ្ងាយណាស់ ។ បើពីមុនអត់មានអីរៀនសូត្រ ឲ្យកូនចៅគ្មានសាលារៀនៗសូត្រ ។ ហើយមកដល់ឥឡូវក៏វាមានសាលារៀនសូត្រ ហើយការគ្រប់គ្រងរៀបចំស្រុកទេសស្រួលបួល ។

ធានី ៖ ពូចូលចិត្តមួយណាជាង ការរស់នៅចិត្តពូ?

ឈាន ៖ រស់នៅដូចសព្វថ្ងៃ ។

ធានី ៖ ចូលចិត្តការរស់នៅសព្វថ្ងៃជាង?

ឈាន ៖ បាទ! យើងប្រកបអាជីវកម្មខ្លួនឯងទៅ ចិញ្ចឹមសត្វចិញ្ចឹមមាន់ធ្វើចំការធ្វើស្រែធម្មតា ។

ធានី ៖ ចង់ទៅណា?

ឈាន ៖ បាទ! ចង់ទៅណាចង់បាន ឲ្យតែយើងមានថវិកាដើរហើរស្រួល មិនដូចពីមុនទេ ពីមុនផ្សេង ។

ធានី ៖ ចុះក្នុងចន្លោះសម័យ៣ឆ្នាំ តើពូដែលធ្លាប់ជួយពីណាគេទេ ជួយផ្តល់ជាចំណីអាហារ ជួយជាយោបល់ ជួយឲ្យរួចជីវិត ឬក៏ជួយស្អីៗ?

ឈាន ៖ ខ្ញុំកាលនោះវាមានយាយចាស់ៗ គាត់ចាស់ជរា ចេះជួយមើលគាត់ ហើយកាលនោះនៅក្នុងសហករណ៍អត់អីហូប ជួយរកដំឡូង ខុះបាយខុះអី ចុះយើងអត់ចេះជួយជីកដំឡូង ។

ធានី ៖ ហូបខ្លួនឯង?

ឈាន ៖ ហូបខ្លួនឯងផង ជួយគាត់ផង ជូនគាត់ចាស់ៗ ។

ធានី ៖ ប៉ុន្មាននាក់ទៅ?

ឈាន ៖ ចាស់ៗ៣-៤-៥នាក់ ប៉ុនគាត់ខូចអស់ហើយ ។

ធានី ៖ ពូជួយគាត់អីចឹង អ្នកផ្សេងគេអត់ស្តីឲ្យ?

ឈាន ៖ អត់ទេ ព្រោះយើងឲ្យគាត់ស្ងាត់ៗ គាត់អត់ហូប ។

ធានី ៖ លក្ខណៈលាក់លៀម?

ឈាន ៖ បាទ!

ធានី ៖ ចាស់ៗ ភាគច្រើនគាត់មកពីណាវិញ?

ឈាន ៖ អ្នកនៅស្រុកភូមិ ។

ធានី ៖ ពូដឹងថាហេតុអីបានអត់សូវហូបគ្រប់គ្រាន់ទេ ព្រោះពូអ្នកធ្វើស្រែនៅនឹង?

ឈាន ៖ ចុះបើជូនកាលធ្វើកើតមិនដឹងយកទៅណា ខ្ញុំអត់ដឹងរឿងគេ ។

ធានី ៖ គ្រាន់ដឹងថាអត់មានអីហូប?

ឈាន ៖ បាទ! តែបើសព្វថ្ងៃនេះវាខុសឆ្ងាយ បានខ្ញុំថារស់នៅសភាពសព្វថ្ងៃវាល្អជាង ខ្ញុំចង់ទៅណាក៏បានៗ ។

ធានី ៖ ទាក់ទងនឹងការផ្សះផ្សា ការធ្វើឲ្យត្រូវរូវគ្នានឹង តើការត្រូវរូវគ្នានឹង យើងធ្វើនៅជិត ឬនៅឆ្ងាយល្អជាង ដើម្បីយើងឆាប់ត្រូវរូវគ្នាទៅវិញទៅមក?

ឈាន ៖ មិនដឹងម៉េចអត់យល់ ។

ធានី ៖ ឧទាហរណ៍ថាកូនពូ២នាក់ឈ្លោះគ្នា ហើយពូចង់ឲ្យកូន២នាក់នឹងឆាប់ត្រូវរូវគ្នាវិញ តើពូគិតថា ដឹបូងគួរតែបំបែកចេញឆ្ងាយ ឬមួយហៅគ្នាមកនិយាយសួរនាំឲ្យត្រូវរូវគ្នា?

ឈាន ៖ ចិត្តខ្ញុំបើថារឿងអីចឹង ចង់ឲ្យជុំគ្នា មកជួបនិយាយគ្នាផ្ទាល់រឿងអីឲ្យច្បាស់លាស់ត្រឹមត្រូវ យើងសួរហេតុផល បានយើងនិយាយល្អទៅ ។ ហេតុផលល្អហើយ អានឹងវាយល់គ្នា វាលែងអីហើយ ។

ធានី ៖ ឲ្យនៅជិតគ្នាល្អដាង?

ឈាន ៖ បាទ! នៅជិតគ្នាល្អដាង ។

ធានី ៖ ពូមានអីចង់បន្ថែមបន្ថែមនូវអ្វីដែលខ្ញុំអត់សួរ ក៏ដូចជាមានចម្ងល់អីទៀត?

ឈាន ៖ គ្មានបន្ថែម គ្មានអីឆ្ងល់ ។

ធានី ៖ ពូមាននៅសល់រូបចាស់ៗ ឬវត្ថុចាស់ៗកាលពីមុននៅសេសសល់ដល់រាល់ថ្ងៃ ជារូបថត ជាឯកសារ ឬជាស្អីក៏ដោយដែលពូគិតថាអានឹងជាចាស់ពីមុនមកសម័យមុន?

ឈាន ៖ អត់មានទេ ខ្ញុំគ្មានដែលថតបានស្អីនឹងគេទេ ។

ធានី ៖ សម័យនៅជំរុំអត់មានដែរ?

ឈាន ៖ បាទ! អត់មានទេ ។ មានតែថតសម័យឥឡូវនេះហើយ ថតរៀបការកូនការអី ។

ធានី ៖ ការកូនឆ្នាំប៉ុន្មាន?

ឈាន ៖ ឆ្នាំប៉ុន្មានការនៅមាត់អូររៀបនៅមាត់អូរ ។

ធានី ៖ ឆ្នាំប៉ុន្មាន?

ឈាន ៖ ៩៦ ៩៧ ។

ធានី ៖ រូបថតColor?

ឈាន ៖ Color ។

ធានី ៖ មិនមែនស-ខ្មៅ?

ឈាន ៖ អត់ទេ អត់មានបាត់អស់ហើយ ។ អានឹងគេមានដាងមានអី ។

ធានី ៖ អរគុណពូច្រើន ។

ឈាន ៖ បាទៗ ។

«ចប់»